# ព្រះរាជក្រម

នស/រកម/០៧១៥/០០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
លេខ [illegible]
ថ្ងៃទី [illegible] ឆ្នាំ២០១៥ ម៉ោង [illegible]
បញ្ជូនទៅ [illegible]

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៧ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងគ្រោះមហន្តរាយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលបំណងគ្រប់គ្រងគ្រោះមហន្តរាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅដូចតទៅ ៖

-ត្រៀមបង្ការ បន្ស៊ាំ កាត់បន្ថយគ្រោះថ្នាក់មុនពេលមានគ្រោះមហន្តរាយដែលបង្កឡើង ដោយធម្មជាតិ ឬមនុស្ស

-ឆ្លើយតប សង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ

-ស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពគ្របដណ្តប់លើការងារគ្រប់គ្រងគ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិ ឬមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចបានកំណត់ ក្នុងសទ្ទានុក្រមជាឧបសម្ព័ន្ធ ។

**មាត្រា ៥.-**

ព្រះរាជាណាចក្រកម្ពុជា ត្រូវប្រារព្ធទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយរួមជាមួយទិវាអាស៊ានគ្រប់គ្រងគ្រោះមហន្តរាយ និងទិវាអន្តរជាតិកាត់បន្ថយគ្រោះមហន្តរាយ ។

កាលបរិច្ឆេទនៃការប្រារព្ធទិវានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ២
# យន្តការគ្រប់គ្រងគ្រោះមហន្តរាយ

**មាត្រា ៦.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលសរសេរជាអក្សរកាត់ថា **គ.ជ.គ.ម.** ជាសេនាធិការឲ្យរាជរដ្ឋាភិបាល ដើម្បីដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារគ្រប់គ្រងគ្រោះមហន្តរាយ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ **គ.ជ.គ.ម.** ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**មាត្រា ៧.–**

**គ.ជ.គ.ម.** ត្រូវមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ប្រតិបត្តិការងារប្រចាំថ្ងៃ ។ អគ្គលេខាធិការដ្ឋាន **គ.ជ.គ.ម.** ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.គ.ម.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨.–**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុង ក្រសួង ស្ថាប័នរបស់ខ្លួន និងត្រូវចាត់ឲ្យមានមន្ត្រីបង្គោលដើម្បីសម្របសម្រួល និងធ្វើការប្រាស្រ័យទាក់ទងជាប្រចាំជាមួយអគ្គលេខាធិការដ្ឋាននៃ **គ.ជ.គ.ម.** ។

**មាត្រា ៩.–**

**គ.ជ.គ.ម.** ត្រូវមានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ក្របខ័ណ្ឌការងារគ្រប់គ្រងគ្រោះមហន្តរាយ

**មាត្រា ១០.–**

សកម្មភាពត្រៀមបង្ការ និងកាត់បន្ថយគ្រោះថ្នាក់ ត្រូវផ្តោតលើដំណាក់កាលមុនពេលមានគ្រោះមហន្តរាយ ដោយស្រាវជ្រាវរកអត្តសញ្ញាណកើតចេញពីមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ កសាងលិខិតបទដ្ឋានគតិយុត្ត និងវិធានការពង្រឹងសមត្ថភាពអប់រំការយល់ដឹងជាសាធារណៈ និងសហប្រតិបត្តិការក្នុងការកសាង និងការអនុវត្តកម្មវិធីបង្ការមុខសញ្ញាគ្រោះថ្នាក់ដែលបង្កើតឲ្យមានហានិភ័យ រួមទាំងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

**មាត្រា ១១.–**

សកម្មភាពត្រៀមរៀបចំ ត្រូវផ្តោតលើដំណាក់កាលមុនពេលកើតមានគ្រោះមហន្តរាយ ដោយចាត់វិធានការរៀបចំបង្កើតប្រព័ន្ធប្រកាសឲ្យដឹងមុន កសាងយុទ្ធសាស្ត្រ និងផែនការត្រៀមបម្រុងឆ្លើយតបសង្គ្រោះបន្ទាន់ ដើម្បីបន្ថយការបាត់បង់ពីគ្រោះមហន្តរាយ នីតិវិធីប្រតិបត្តិការជាគំរូក្នុងកិច្ចប្រតិបត្តិការជំនួយគ្រោះមហន្តរាយ ធ្វើលំហាត់ទ្រឹស្តី លំហាត់សមយុទ្ធ ។

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

**មាត្រា ១២.-**

សកម្មភាពឆ្លើយតប សង្គ្រោះបន្ទាន់ ត្រូវផ្ដោតលើដំណាក់កាលក្នុងពេលមានគ្រោះមហន្តរាយ ដោយចាត់វិធានការបន្ទាន់ដឹកនាំសម្របសម្រួលបញ្ជារាល់ប្រតិបត្តិការ ឆ្លើយតបសង្គ្រោះបន្ទាន់ ទប់ស្កាត់ការរីករាលដាលនៃមុខសញ្ញាគ្រោះថ្នាក់ កៀរគរជំនួយមនុស្សធម៌ និងគ្រឿងបរិក្ខារ មូលដ្ឋានសម្ភារៈ ធនធានមនុស្ស និងហិរញ្ញវត្ថុ សម្រាប់ជំនួយគ្រោះមហន្តរាយ ។

**មាត្រា ១៣.-**

សកម្មភាពស្តារឡើងវិញត្រូវផ្ដោតលើដំណាក់កាលក្រោយពេលមានគ្រោះមហន្តរាយ ដោយធ្វើឲ្យប្រសើរឡើងវិញ និងកសាងឡើងវិញ ។

## ជំពូកទី ៤
## ការដឹកនាំគ្រប់គ្រង

**មាត្រា ១៤.-**

**គ.ជ.គ.ម.** និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ ត្រូវចាត់វិធានការសមស្រប ក្នុងការកំណត់អត្តសញ្ញាណហានិភ័យគ្រោះមហន្តរាយ និងសមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងតម្រូវឲ្យមានការវិភាគហានិភ័យគ្រោះមហន្តរាយចំពោះសកម្មភាពអភិវឌ្ឍន៍ណាមួយដែលបង្កឲ្យមានហានិភ័យខ្ពស់ ។

**មាត្រា ១៥.-**

**គ.ជ.គ.ម.** ត្រូវសម្របសម្រួលសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ ជាមួយក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ ផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិលក្នុងការលើកកម្ពស់សុវត្ថិភាព និងភាពធន់ទៅនឹងគ្រោះមហន្តរាយ ។ **គ.ជ.គ.ម.** ត្រូវលើកសំណើជូនរាជរដ្ឋាភិបាល ពិនិត្យលទ្ធភាពទប់ស្កាត់ និងតវ៉ាដល់អ្នកពាក់ព័ន្ធទាំងឡាយ ទាំងនៅក្នុងប្រទេស និងក្រៅប្រទេសឲ្យទទួលខុសត្រូវពីផលប៉ះពាល់នៃគ្រោះមហន្តរាយដែលបុគ្គល ឬស្ថាប័ន បានបង្កបង្កើតឡើង ។

**មាត្រា ១៦.-**

**គ.ជ.គ.ម.** ត្រូវចេញគោលការណ៍ណែនាំដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ ផ្នែកសាធារណៈ ផ្នែកឯកជន សង្គម ស៊ីវិលឲ្យធ្វើការសិក្សាប៉ាន់ប្រមាណហានិភ័យ និងរិះរកវិធានការ វិធីសាស្ត្រ និងបច្ចេកទេស ដែលចាំបាច់សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

**មាត្រា ១៧.-**

**គ.ជ.គ.ម.** ត្រូវចេញគោលការណ៍ណែនាំដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ ផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិលក្នុងការកសាងផែនការត្រៀមបម្រុង និងការរៀបចំបម្រុងទុកទ្រព្យសម្បត្តិសម្រាប់ជំនួយគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ ។

**មាត្រា ១៨.-**

ក្នុងករណីដែលមានព្រឹត្តិការណ៍ ឬឧបទ្ទវហេតុកើតឡើង អាជ្ញាធរមានសមត្ថកិច្ចដែលមានទីតាំងនៅតំបន់កើតហេតុត្រូវ ៖

-ធ្វើប្រតិបត្តិការសង្គ្រោះបន្ទាន់ រុករក សង្គ្រោះ ផ្តល់ការថែទាំវេជ្ជសាស្ត្រ និងការពារអាយុជីវិតប្រជាពលរដ្ឋរងគ្រោះ

-យកចិត្តទុកដាក់ខ្ពស់លើតម្រូវការរបស់ស្ត្រី កុមារ ចាស់ជរា ជនពិការ និងជនបាត់បង់លទ្ធភាពពលកម្ម

-ទប់ស្កាត់ការរាលដាលហាយនភាព និងហានិភ័យផ្សេងៗ

-រាយការណ៍បន្ទាន់អំពីស្ថានភាពគ្រោះមហន្តរាយទៅអាជ្ញាធរដែនដី និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៃតំបន់កើតហេតុ

-គ្រប់គ្រងស្ថានការណ៍ទូទៅរហូតដល់ផ្ទេរសមត្ថកិច្ចដឹកនាំ និងចាត់ចែងទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ដែលមកទទួលខុសត្រូវបន្ត

-បន្តជួយក្នុងប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយតាមសំណូមពររបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយដែលទទួលខុសត្រូវ ។

**មាត្រា ១៩.-**

ត្រូវចាត់ទុកជាការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ នៅពេលដែលគ្រោះមហន្តរាយនោះបានកើតឡើងតែនៅក្នុងដែនរដ្ឋបាល ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ណាមួយ ។

ត្រូវចាត់ទុកជាការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត នៅពេលដែលគ្រោះមហន្តរាយនោះប៉ះពាល់ដល់ក្រុង ស្រុក ខណ្ឌ លើសពីមួយ ឬកើតឡើង ក្នុងក្រុង ស្រុក ខណ្ឌនានា នៃរាជធានី ខេត្ត ។

**មាត្រា ២០.-**

នៅពេលទទួលបានព័ត៌មានទាក់ទងនឹងគ្រោះមហន្តរាយណាមួយ **គ.ជ.គ.ម.** ត្រូវដំណើរការប្រតិបត្តិការសង្គ្រោះបន្ទាន់ និងចាត់បញ្ជូនក្រុមប៉ាន់ប្រមាណរហ័សទៅកាន់តំបន់រងគ្រោះដើម្បី

សម្របសម្រួលប៉ាន់ប្រមាណ និងការឆ្លើយតបគ្រោះមហន្តរាយ ដោយរួមសហការជាមួយក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ ផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធចាំបាច់ដទៃទៀត ។

**គ.ជ.គ.ម.** ត្រូវជួបប្រជុំគ្រប់ភាគីពាក់ព័ន្ធ ពិភាក្សាអំពីការឆ្លើយតប លើកជាសំណើ និងវិធានការចាំបាច់នានាជូនដល់រាជរដ្ឋាភិបាល ដើម្បីធ្វើការសម្រេចចិត្តប្រកាសអំពីគ្រោះមហន្តរាយ និងចាត់វិធានការនានាទាក់ទងនឹងប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយ ។

**មាត្រា ២១.-**

ក្នុងករណីដែលគ្រោះមហន្តរាយមានទំហំធំ រាជរដ្ឋាភិបាលត្រូវ ៖

-ដាក់តំបន់រងគ្រោះស្ថិតនៅក្រោមស្ថានភាពគ្រោះមហន្តរាយក្នុងថិរវេលាកំណត់

-កៀរគរកម្លាំងក្នុងប្រទេសដើម្បីសង្គ្រោះបន្ទាន់ និងឆ្លើយតបគ្រោះមហន្តរាយ

-ដាក់ចេញនូវបទបញ្ជា និងវិធានការពិសេសសម្រាប់គ្រោះមហន្តរាយ

-ដាក់តំបន់រងគ្រោះឲ្យស្ថិតក្នុងស្ថានភាពប្រក្រតីវិញ នៅពេលដែលតំបន់រងគ្រោះនោះបានរួចផុតពីគ្រោះអាសន្ន ។

ការដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ត្រូវអនុលោមតាមរដ្ឋធម្មនុញ្ញ ក្នុងករណីដែលស្ថានភាពគ្រោះមហន្តរាយ និងការគម្រាមកំហែងរីករាលដាលដល់កម្រិតទូទាំងប្រទេស ។

**មាត្រា ២២.-**

ក្នុងករណីដែលវិសាលភាពនៃគ្រោះមហន្តរាយមានទំហំហួសពីសមត្ថភាព និងលទ្ធភាពឆ្លើយតបរបស់ខ្លួន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវ ត្រូវជូនដំណឹងជាបន្ទាន់ទៅ **គ.ជ.គ.ម.** ដើម្បីសុំយោបល់ និងការជួយអន្តរាគមន៍ ឬចលនាជំនួយមនុស្សធម៌ដើម្បីឆ្លើយតបតាមការជាក់ស្តែង ។

ករណីមានតម្រូវការចាំបាច់ **គ.ជ.គ.ម.** ត្រូវស្នើសុំរាជរដ្ឋាភិបាលផ្តល់អន្តរាគមន៍បន្ទាន់ និងអំពាវនាវដល់ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ ផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិលឲ្យជួយក្នុងប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយ ។

**មាត្រា ២៣.-**

ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ ផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិលត្រូវចូលរួមក្នុងប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយ តាមការស្នើសុំរបស់អាជ្ញាធរមានសមត្ថកិច្ច និង **គ.ជ.គ.ម.** ដោយផ្តល់ធនធានមនុស្ស សម្ភារៈ បរិក្ខារ ថវិកា និងបច្ចេកទេសដល់ប្រតិបត្តិការនានា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ម្ចាស់ ២០០០

**មាត្រា ២៤.-**

អង្គការអន្តរជាតិ តំណាងបេសកកម្ម និងស្ថានទូតបរទេសដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមាននិវេសនដ្ឋាននៅបរទេសអាចចូលរួមក្នុងប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយ ។

**មាត្រា ២៥.-**

ក្រោយពីមានការប្រកាសដាក់ប្រទេស ឬតំបន់ស្ថិតនៅក្រោមស្ថានភាពគ្រោះមហន្តរាយដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ និងដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាល រដ្ឋបាលនៅនឹងកន្លែង និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវមានសិទ្ធិក្នុងការធ្វើកំណែនពលរដ្ឋ ទ្រព្យសម្បត្តិឯកជន ទ្រព្យសម្បត្តិរដ្ឋ ដើម្បីប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយ និងស្នើឲ្យក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ ផ្នែកសាធារណៈ ផ្នែកឯកជន និងមន្ទីរពេទ្យ ផ្តល់សេវាជំនាញ ផ្តល់ទីតាំងឲ្យអ្នករងគ្រោះស្នាក់អាស្រ័យ និងទទួលព្យាបាលដោយគ្មានលក្ខខណ្ឌ ។

នីតិវិធីនៃការធ្វើកំណែន និងសំណង ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២៦.-**

រាល់កំណែនទ្រព្យសម្បត្តិឯកជន ទ្រព្យសម្បត្តិរដ្ឋ ដើម្បីប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយ ដែលត្រូវបានធ្វើឡើងដោយរដ្ឋបាលនៅនឹងកន្លែង និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ តាមរយៈការប្រើប្រាស់សិទ្ធិពិសេសរបស់ខ្លួន ត្រូវបានផ្តល់សំណងវិញ ។

**មាត្រា ២៧.-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅនឹងកន្លែង ត្រូវដឹកនាំសម្របសម្រួល ការប៉ាន់ប្រមាណ ការខូចខាត ការបាត់បង់ និងតម្រូវការស្តារឡើងវិញ នៅក្នុងដែនរដ្ឋបាលរបស់ខ្លួនដែលរងគ្រោះ និងចូលរួមក្នុងការកសាងផែនការ និងគម្រោងស្តារឡើងវិញ សម្រាប់តំបន់ដែលរងគ្រោះដោយផ្តោតលើអាទិភាពនៃតម្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ និងសហគមន៍ដែលរងគ្រោះ ។

**គ.ជ.គ.ម.** មានភារកិច្ចដឹកនាំ និងសម្របសម្រួលការសិក្សា ប៉ាន់ប្រមាណការខូចខាត ការបាត់បង់ និងតម្រូវការស្តារឡើងវិញក្រោយគ្រោះមហន្តរាយ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន អង្គភាពជំនាញ ភាគីពាក់ព័ន្ធ និងរៀបចំផែនការ និងគម្រោងស្តារឡើងវិញដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេច ។ របាយការណ៍ប៉ាន់ប្រមាណ ផែនការ និងគម្រោងស្តារឡើងវិញ អាចចែករំលែកជាមួយក្រសួង ស្ថាប័ន ផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិល ស្ថានទូត ប្រទេសនានា និងសប្បុរសជនឲ្យចូលរួមក្នុងការស្តារឡើងវិញ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី ៥
# កិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ

**មាត្រា ២៨.-**

ក្នុងនាមរាជរដ្ឋាភិបាល **គ.ជ.គ.ម.** ជាអ្នកដឹកនាំសម្របសម្រួល និងអនុវត្តកិច្ចសហប្រតិបត្តិការ កិច្ចសហការ និងជំនួយជាថវិកា ធនធាន និងសម្ភារៈអន្តរជាតិក្នុងការគ្រប់គ្រងគ្រោះមហន្តរាយបូករួមទាំងការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិលើការងារគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបចម្រុះអន្តរជាតិក្នុងគ្រាមានគ្រោះអាសន្ន និង/ឬគ្រោះមហន្តរាយ ។

**មាត្រា ២៩.-**

សប្បុរសជន អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ តំណាងបេសកកម្ម និងស្ថានទូតបរទេសអាចគាំទ្រ និងផ្តល់ជំនួយដល់សកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបមនុស្សធម៌ ក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈ **គ.ជ.គ.ម.** ។

**មាត្រា ៣០.-**

**គ.ជ.គ.ម.** ត្រូវរៀបចំប្រព័ន្ធដើម្បីផ្តល់ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងជំនួយអន្តរជាតិសម្រាប់សកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយឲ្យមានតម្លាភាព និងប្រសិទ្ធភាព ។

**មាត្រា ៣១.-**

រាល់ពន្ធ និងអាករលើជំនួយសម្រាប់សកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបមនុស្សធម៌ ដែលបានផ្តល់មកឲ្យកម្ពុជា ជាបន្ទុករបស់រដ្ឋ ។

**មាត្រា ៣២.-**

ក្នុងករណីគ្រោះមហន្តរាយមានវិសាលភាពធំធេងលើសពីលទ្ធភាពឆ្លើយតបរបស់ប្រទេស រាជរដ្ឋាភិបាល តាមសំណើរបស់ **គ.ជ.គ.ម.** ត្រូវធ្វើការអំពាវនាវដល់សហគមន៍អន្តរជាតិ ដើម្បីសុំជំនួយឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ ។

បន្ទាប់ពីមានការប្រកាសផ្តល់ជំនួយពីសហគមន៍អន្តរជាតិ **គ.ជ.គ.ម.** អាច ៖

១- ប្រកាសទទួលយកជំនួយអន្តរជាតិ ។

២- បញ្ជាឲ្យគ្រប់អាជ្ញាធរមានសមត្ថកិច្ចធ្វើកិច្ចសហការ និងកិច្ចសហប្រតិបត្តិការជាមួយម្ចាស់ជំនួយ និងក្រុមឆ្លើយតបអន្តរជាតិក្នុងប្រតិបត្តិការឆ្លើយតប ។

៣- អនុញ្ញាតឲ្យប្រើប្រាស់ជំនួយអន្តរជាតិដែលបានបញ្ជូនមកក្នុងប្រទេសតាម ច្បាប់ បទបញ្ញា និងនីតិវិធីពិសេស ។

ការស្តារឡើងវិញដែលបានមកពីហិរញ្ញប្បទានឥតសំណង ឬឥណទានសម្បទាន ត្រូវប្រព្រឹត្តទៅស្របតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

**មាត្រា ៣៣.-**

បុគ្គល ឬស្ថាប័នអន្តរជាតិដែលមានបំណងផ្តល់ជំនួយជាថវិកា ធនធាន និងសម្ភារៈដល់ព្រះរាជាណាចក្រកម្ពុជា និងក្រុមឆ្លើយតបអន្តរជាតិ ត្រូវជូនដំណឹងមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងផ្តល់ព័ត៌មានមក **គ.ជ.គ.ម.** អំពីជំនួយ ថវិកា ធនធាន និងសម្ភារៈ ចំនួនមនុស្ស ជំនាញ ដែលត្រូវប្រើប្រាស់ក្នុងប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ។

ភ្នាក់ងារជំនួយអន្តរជាតិ និងបុគ្គលិកឆ្លើយតបអន្តរជាតិ ដែលបានចូលមកបំពេញការងារឆ្លើយតបគ្រោះមហន្តរាយនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពច្បាប់ បទបញ្ញា វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់ព្រះរាជាណាចក្រកម្ពុជា និងត្រូវសហការជាមួយ **គ.ជ.គ.ម.** ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច និងសហគមន៍ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

**មាត្រា ៣៤.-**

**គ.ជ.គ.ម.** ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសម្រួលរាល់នីតិវិធីការងារចាំបាច់ដើម្បីជួយគាំទ្រ និងផ្តល់ការជួយជ្រោមជ្រែងដល់ការចូលមកបំពេញការងាររបស់បុគ្គលិកក្រុមឆ្លើយតបអន្តរជាតិ ការនាំចូលសម្ភារៈ ឧបករណ៍ មធ្យោបាយ និងជំនួយមនុស្សធម៌ ក៏ដូចជាការចុះបញ្ជីស្ថាប័នអន្តរជាតិទាំងនោះ ព្រមទាំងការផ្តល់ទិដ្ឋាការ និងសេវាកម្មផ្សេងៗទៀតតាមការចាំបាច់ ។

នីតិវិធីដោយឡែកស្តីពីការផ្តល់ទិដ្ឋាការដល់បុគ្គលិកក្រុមឆ្លើយតបអន្តរជាតិ ការនាំចូល សម្ភារៈ ឧបករណ៍ មធ្យោបាយ និងជំនួយមនុស្សធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៦
## សិទ្ធិ និងភារកិច្ច

**មាត្រា ៣៥.-**

បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការការពារអាយុជីវិត សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងជំនួយសង្គ្រោះ នៅក្នុងពេលមានគ្រោះមហន្តរាយ ។

បុគ្គលគ្រប់រូបមានសិទ្ធិទទួលបាននូវព័ត៌មានស្តីពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះហានិភ័យ វិធីសាស្ត្រ បច្ចេកទេសសម្រាប់ការពារខ្លួន និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការត្រៀមបង្ការ ការឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ ។

ពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិទទួលបានធនធានសម្រាប់អនុវត្តវិធានការការពារ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដើម្បីស្តារជីវភាពរស់នៅឡើងវិញ ក្រោយគ្រោះមហន្តរាយ ។



**មាត្រា ៣៦.-**

បុគ្គលគ្រប់រូបមានសិទ្ធិចូលរួមក្នុងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ និងលើកកម្ពស់ភាពម្ចាស់ការក្នុងការការពារ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការធានានិរន្តរភាព ជីវភាពរស់នៅប្រកបដោយសុវត្ថិភាព និងភាពធន់ទៅនឹងគ្រោះមហន្តរាយ ។

**មាត្រា ៣៧.-**

រូបវន្តបុគ្គល និងនីតិបុគ្គលមានកាតព្វកិច្ចចូលរួមក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការត្រៀមបង្ការ ការត្រៀមរៀបចំ ការឆ្លើយតប ការសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ ដោយត្រូវ ៖

-គោរពច្បាប់ បទបញ្ជា និងសេចក្តីណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ដោយរាយការណ៍ព័ត៌មានបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច អំពីស្ថានភាពហានិភ័យដែលអាចបង្កឲ្យមានគ្រោះមហន្តរាយ

-ថែរក្សាបរិស្ថានរស់នៅ បរិស្ថានធម្មជាតិ និងសាមគ្គីភាពក្នុងសហគមន៍ ។

## ជំពូកទី ៧
## ប្រភពធនធាននិងមូលនិធិ

**មាត្រា ៣៨.-**

ការចំណាយសម្រាប់ដំណើរការរបស់ **គ.ជ.គ.ម.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**គ.ជ.គ.ម.** មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធាន និងមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន ។

**មាត្រា ៣៩.-**

រដ្ឋត្រូវមានថវិកា និងធនធានបម្រុងសមស្របសម្រាប់ធានាការគ្រប់គ្រងគ្រោះមហន្តរាយ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៤០.-**

អំពើចូលទៅក្នុង ឬចេញពីតំបន់ហាមឃាត់ដែលត្រូវបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងកិច្ចប្រតិបត្តិការពេលមានគ្រោះមហន្តរាយ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមាន សមត្ថកិច្ច ត្រូវ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និង/ឬពិន័យជាប្រាក់ពី ៥០ ០០០ (ប្រាំម៉ឺន) រៀល ទៅ ៥០០ ០០០ (ហាសិបម៉ឺន) រៀល ។

**មាត្រា ៤១.-**

អំពើដោយចេតនារារាំង ឬបង្កឧបសគ្គដល់កិច្ចប្រតិបត្តិការសង្គ្រោះបន្ទាន់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និង/ឬពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០(ពីរលាន) រៀល ។

**មាត្រា ៤២.-**

អំពើដោយចេតនាមិនគោរពបញ្ជារបស់រដ្ឋបាលនៅនឹងកន្លែង ឬគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយដែលប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនក្រោមបញ្ញត្តិ នៃមាត្រា ២៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១(មួយ)ឆ្នាំ និង/ឬពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។

**មាត្រា ៤៣.-**

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៤២ ខាងលើនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចមានចែងក្នុងមាត្រា ២០៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៤៤.-**

រាល់បុគ្គលដែលបានដឹងអំពីស្ថានភាពហានិភ័យដែលអាចបង្កឲ្យមានគ្រោះមហន្តរាយហើយមិនបានរាយការណ៍ព័ត៌មានជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ៦ (ប្រាំមួយ) ខែ និង/ឬពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន) រៀល ទៅ១ ០០០ ០០០ (មួយលាន) រៀល ។

**មាត្រា ៤៥.-**

មន្ត្រីសមត្ថកិច្ចគ្រប់គ្រងគ្រោះមហន្តរាយ ដែលខ្វះការទទួលខុសត្រូវ មិនបំពេញភារកិច្ច

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឬបំពេញភារកិច្ចដោយមិនត្រឹមត្រូវ ក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរ ដល់ទ្រព្យសម្បត្តិឯកជន ឬសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន)រៀល ទៅ៤ ០០០ ០០០ (បួនលាន) រៀល ។

## ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ៤៦.-**

ក្រោយពេលដែលច្បាប់នេះចូលជាធរមាន លិខិតបទដ្ឋានគតិយុត្តនានាដែលកំពុងអនុវត្ត ត្រូវបន្តមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ។

រាល់កម្មវិធី និងសកម្មភាពដែលទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវមានសុពលភាពរហូតដល់ថ្ងៃផុតកំណត់នៃកម្មវិធី និងសកម្មភាពទាំងនោះ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៤៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤៨.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នសរកម. ០៧១៥. ០១៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**និងជាអនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

**ហត្ថលេខា**

**ញឹម វណ្ណដា**

សំណៅថតចម្លងមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

សយ សុខា

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
## សទ្ទានុក្រម

**ការគ្រប់គ្រងគ្រោះមហន្តរាយ** សំដៅដល់សកម្មភាពមួយចំនួនមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ ដើម្បីថែរក្សាការត្រួតពិនិត្យតាមដានពីគ្រោះមហន្តរាយ និងផ្តល់ក្របខ័ណ្ឌការងារសម្រាប់ជួយដល់មនុស្ស ដែលស្ថិតក្នុងហានិភ័យ ឬសហគមន៍ណាមួយ ដើម្បីបញ្ចៀសកាត់បន្ថយជាអប្បបរមា ឬធ្វើឲ្យមានប្រក្រតីភាពឡើងវិញពីផលប៉ះពាល់ នៃគ្រោះមហន្តរាយ ។

**ការកាត់បន្ថយគ្រោះថ្នាក់** សំដៅដល់វិធានការបែបរចនាសម្ព័ន្ធ និងបែបមិនមែនរចនាសម្ព័ន្ធ ដើម្បីទទួលធ្វើ ដើម្បីកម្រិតផលប៉ះពាល់មិនល្អនៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ការខូចខាតបរិស្ថាន និងមុខសញ្ញាគ្រោះថ្នាក់ខាងបច្ចេកទេស ។ ឧទាហរណ៍ វិធានការបែប រចនាសម្ព័ន្ធ ជាការងារវិស្វកម្ម ការកសាងទប់ទល់មុខសញ្ញាគ្រោះថ្នាក់ ចំណែកវិធានការបែប មិនមែនរចនាសម្ព័ន្ធរួមមានការបង្កើនការយល់ដឹង ការអភិវឌ្ឍចំណេះដឹង គោលនយោបាយ ផែនការប្រើប្រាស់ដី និងគ្រប់គ្រងធនធាន និងការអនុវត្តប្រតិបត្តិការមធ្យោបាយនានា ។

**ការត្រៀមបង្ការ** សំដៅដល់សកម្មភាព ដើម្បីបញ្ចៀសទាំងស្រុងពីផលប៉ះពាល់បណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់ និងជាមធ្យោបាយ ដើម្បីបន្ថយជាអតិបរមាទាក់ទងនឹងគ្រោះមហន្តរាយ នៃបរិស្ថាន បច្ចេកវិទ្យា និងជីវសាស្ត្រ ។

**ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ** សំដៅដល់ទស្សនាទាន និងការអនុវត្តតាមរយៈការខិតខំប្រឹងប្រែងជាប្រព័ន្ធដើម្បីវិភាគ និងគ្រប់គ្រងកត្តាដែលអាចកើតមានគ្រោះមហន្តរាយ រួមទាំងការកាត់បន្ថយកម្រិតគ្រោះថ្នាក់នៃមុខសញ្ញាគ្រោះថ្នាក់ ធ្វើឲ្យតិចនូវភាពងាយរងគ្រោះរបស់មនុស្ស និងទ្រព្យសម្បត្តិ របៀបគ្រប់គ្រងដីធ្លី បរិស្ថាន និងពង្រឹងការត្រៀមរៀបចំសម្រាប់ព្រឹត្តិការណ៍អាក្រក់នានា ។

**ការយល់ដឹងជាសាធារណៈ** សំដៅដល់ការពង្រីកចំណេះដឹងទូទៅអំពីហានិភ័យ គ្រោះមហន្តរាយ ដែលជាកត្តានាំឲ្យមានគ្រោះមហន្តរាយ និងសកម្មភាពអាចអនុវត្តបានដោយបុគ្គល និងដោយសមូហភាព ដើម្បីកាត់បន្ថយការប្រឈមមុខនឹងភាពងាយរងគ្រោះទៅនឹងមុខសញ្ញាគ្រោះថ្នាក់នានា ។

**ការឆ្លើយតប** សំដៅដល់ការផ្តល់សេវាកម្មសង្គ្រោះបន្ទាន់ និងជំនួយសាធារណៈនៅក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ ដើម្បីជួយសង្គ្រោះជីវិត កាត់បន្ថយផលប៉ះពាល់ លើសុខភាព ធានាសុវត្ថិភាពសាធារណៈ និងដោះស្រាយសេចក្តីត្រូវការសម្រាប់ការចិញ្ចឹមជីវិតជាមូលដ្ឋានរបស់ប្រជាជនដែលទទួលរងផលប៉ះពាល់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ការប៉ាន់ប្រមាណហានិភ័យ** សំដៅដល់វិធីសាស្ត្រដើម្បីកំណត់លក្ខណៈ និងកម្រិតនៃហានិភ័យ ដោយធ្វើការវិភាគមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមាន និងវាយតម្លៃលើលក្ខខណ្ឌដែលមានស្រាប់នៃភាពងាយរងគ្រោះ ដែលកត្តាទាំពីរនេះអាចបង្កមហន្តរាយដល់ មនុស្ស ទ្រព្យសម្បត្តិ សេវាកម្មជីវភាពរស់នៅ និងបរិស្ថាន ។

**គ្រោះមហន្តរាយ** សំដៅដល់ការរំខានធ្ងន់ធ្ងរនៃដំណើរការរបស់សហគមន៍ ឬសង្គមដែលធ្វើឲ្យមានការបាត់បង់និងប៉ះពាល់ធ្ងន់ធ្ងរដល់មនុស្ស សម្ភារៈ សេដ្ឋកិច្ច ឬបរិស្ថាន ហើយកម្រិតនៃការប៉ះពាល់ហួសពីលទ្ធភាពរបស់សហគមន៍ ឬសង្គមដែលទទួលរងការប៉ះពាល់ក្នុងការប្រើប្រាស់លៃលកដោះស្រាយដោយធនធានខ្លួនឯង ។

**គ្រោះអាសន្ន** សំដៅដល់ការគំរាមកំហែងដែលតម្រូវឲ្យមានសកម្មភាពបន្ទាន់ប្រកបដោយប្រសិទ្ធភាព ដែលអាចបញ្ចៀសនូវការរីកធំឡើងនៃព្រឹត្តិការណ៍ដែលឈានដល់គ្រោះមហន្តរាយ ។

**ប្រព័ន្ធប្រកាសឲ្យដឹងមុន** សំដៅដល់សមត្ថភាពដែលតម្រូវឲ្យមានការបង្កើនសម្រាប់ប្រមូល និងផ្សព្វផ្សាយទាន់ពេលវេលា និងប្រកាសព័ត៌មានដែលមានន័យគ្រប់គ្រាន់ទៅដល់ក្រុមមនុស្ស សហគមន៍ និងស្ថាប័នដែលគម្រាមកំហែងដោយមុខសញ្ញាគ្រោះថ្នាក់ ដើម្បីត្រៀមធ្វើឲ្យសមស្រប និងទាន់ពេលវេលាពីការកាត់បន្ថយលទ្ធភាពនៃការអន្តរាយ ឬបាត់បង់ ។

**ផែនការត្រៀមបម្រុង** សំដៅដល់ការគ្រប់គ្រងដំណើរការដែលធ្វើការវិភាគលើព្រឹត្តិការណ៍កើតឡើង ឬស្ថានភាពអាចកើតឡើង ហើយអាចគំរាមសង្គម ឬបរិស្ថាន និងការរៀបចំទុកដាក់ដើម្បីចាត់ចែងពេលខាងមុខប្រកបដោយសមត្ថភាព និងទាន់ពេលទៅនឹងព្រឹត្តិការណ៍ និងស្ថានភាពទាំងនោះ ។

**ភាពងាយរងគ្រោះ** សំដៅដល់លក្ខខណ្ឌដែលកំណត់ដោយកត្តារូបវន្ត សង្គម សេដ្ឋកិច្ច និងបរិស្ថាន ឬជាដំណើរការដែលបង្កើនភាពចុះខ្សោយរបស់សហគមន៍ទៅនឹងផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ ។

**ភាពធន់** សំដៅដល់សមត្ថភាពប្រព័ន្ធ សហគមន៍ ឬសង្គមដែលប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ ដើម្បីទប់ទល់សម្របទៅតាមនិងស្តារពីផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ឲ្យបានទាន់ពេល និងមានប្រសិទ្ធភាព តាមរយៈសកម្មភាពនានា ដោយសិក្សាពីគ្រោះមហន្តរាយ ពីអតីតកាលឲ្យមានការប្រុងប្រយ័ត្ននាពេលអនាគត និងចាត់វិធានការឲ្យប្រសើរឡើងនូវការកាត់បន្ថយហានិភ័យ ។

**មុខសញ្ញាគ្រោះថ្នាក់** សំដៅដល់ព្រឹត្តិការណ៍មួយ បាតុភូតមួយ ឬសកម្មភាពរបស់ មនុស្សដែលសក្តានុភាពអាចធ្វើឲ្យខូចខាតជារូបវន្ត រួមមានការបាត់បង់អាយុជីវិត រងរបួស ខូចខាត និងបាត់បង់ទ្រព្យសម្បត្តិ រាំងស្ទះដល់សង្គម និងសេដ្ឋកិច្ច ឬខូចខាតបរិស្ថាន ។



ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**ហានិភ័យ** សំដៅដល់ភាពដែលអាចកើតមាននូវផលវិបាក ការធ្វើទុក្ខទោស ឬការបាត់បង់ដែលបានរំពឹងទុក( ស្លាប់ របួស ទ្រព្យសម្បត្តិ ជីវភាព សកម្មភាពសេដ្ឋកិច្ចត្រូវបាន រំខាន ឬបរិស្ថាន ត្រូវបានខូចខាត) ដែលបណ្តាលមកពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ឬមនុស្សទៅនឹងភាពងាយរងគ្រោះ ។

**ហានិភ័យគ្រោះមហន្តរាយ** សំដៅដល់អានុភាពនៃការបាត់បង់ដោយគ្រោះមហន្តរាយ លើអាយុជីវិត សុខភាព ជីវភាពរស់នៅ ទ្រព្យសម្បត្តិ និងសេវាកម្មនានា ដែលអាចកើតឡើងចំពោះសហគមន៍ ឬសង្គមនៅពេលមួយក្នុងពេលអនាគត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL